# សេចក្តីថ្លែងការរួម

## សិក្ខាសាលាថ្នាក់ជាតិ ស្តីពី ការព្រួយបារម្ភណ៍ចំពោះគម្រោងទំនប់វារីអគ្គិសនី «ដនសាហុង»

## ថ្ងៃ២០ ខែមីនា ឆ្នាំ២០១៤

## សូមគោរពជូន

- **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- **នាយករដ្ឋមន្ត្រីនៃប្រជាមានិតវៀតណាម**
- **នាយករដ្ឋមន្ត្រីនៃប្រទេសថៃ**
- **នាយករដ្ឋមន្ត្រីនៃប្រជាមានិតប្រជាធិបតេយ្យឡាវ**

ទំនប់វារីអគ្គិសនី ដនសាហុង ដែលមានថាមពល ២៦០ម៉េហ្គាវ៉ាត់ គឺជាទំនប់មួយក្នុងចំណោមគម្រោងទំនប់វារីអគ្គិសនីទាំង១២ដែលគ្រោងសាងសង់នៅតួទន្លេមេនៃទន្លេមេគង្គក្រោម។ បច្ចុប្បន្នវាកំពុងត្រូវបានចាប់ផ្តើមសិក្សា និងដាក់សំណើសម្រាប់ការសាងសង់បន្ទាប់ពីទំនប់វារីអគ្គិសនី សាយ៉ាបូរី។ វាមានទីតាំងស្ថិតនៅចំងាយ ២ គីឡូម៉ែត្រ ពីព្រំដែនកម្ពុជា-ឡាវ ក្នុងខេត្ត ចំប៉ាសាក់ ប្រទេសឡាវ។ អគ្គិសនីបានពីទំនប់ដងសាហុង ត្រូវបានគ្រោងទុកសំរាប់នាំចេញទៅកាន់ប្រទេសថៃ។ ប្រសិនបើទំនប់ត្រូវបានសាងសង់វានឹងរាំងខ្ទប់ដៃទន្លេ ហូសាហុង ដែលជាដៃទន្លេដ៏ធំមួយដែលរួមនឹងផ្នែកល្បាក់ខោននៃទន្លេមេគង្គក្រោម។

អង្គការវេទិការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សហការជាមួយសម្ព័ន្ធទន្លេកម្ពុជា (RCC) បានរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយស្តីពី «ការព្រួយបារម្ភណ៍ចំពោះទំនប់វារីអគ្គិសនីដនសាហុង» នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ ដើម្បីផ្តល់ឱកាសសម្រាប់អ្នកពាក់ព័ន្ធរួមមាន រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល តំណាងសហគមន៍ ពិភាក្សាពីសារៈសំខាន់នៃទន្លេមេគង្គ និងបញ្ហាប្រឈមមុខ ចំពោះជីវភាពរបស់ពួកគាត់ដែលអាចប៉ះពាល់ពីទំនប់ដនសាហុង។

គោលបំណងចំបងនៃសិក្ខាសាលានេះ គឺចែករំលែកព័ត៌មាន បង្កើនការស្វែងយល់ពីទំនប់ដនសាហុង និងផលប៉ះពាល់ជាអាទិភាពរបស់វាចំពោះជីវភាពសហគមន៍ដែលរស់នៅតាមបឹងទន្លេសាប និងទន្លេមេគង្គ។ នៅក្នុងពេលដំណើការសិក្ខាសាលា អ្នកចូលរួមបានលើកឡើងពីក្តីបារម្ភលើផលប៉ះពាល់ដែលអាចកើតមានពីទំនប់ ដែលផលប៉ះពាល់ទាំងនោះរួចបញ្ចូលទាំងផលប៉ះពាល់លើជីវភាពរស់នៅប្រចាំថ្ងៃ និងសុវត្ថិភាពស្បៀង ការបាត់បង់នូវធនធានធម្មជាតិ បញ្ហាសន្តិសុខ និងហានិភ័យផ្សេងៗ បញ្ហាសុខភាពសហគមន៍ និងកង្វះភាពនៃគុណភាពរបស់ការសិក្សាពីផលប៉ះពាល់ និងការពិគ្រោះយោបល់ជាមួយសហគមន៍។ អ្នកចូលរួមក៏លើកឡើងនូវសំណូមពរល្អៗជាច្រើនផងដែរ សូមពិនិត្យមើលក្នុងឯកសារភ្ជាប់ពីក្តីបារម្ភ និងសំណូមលំអិតបន្ថែមទៀត។

*"ប្រសិនបើទំនប់ដនសាហុងត្រូវបានសាងសង់ នាងខ្ញុំមានក្តីបារម្ភថា នឹងមិនមានត្រីសម្រាប់នេសាទទេ ហើយនាងខ្ញុំគឺមិនអាចចិញ្ចឹមកូនៗរបស់ខ្ញុំបានដែរ។ នាងខ្ញុំមានការព្រួយបារម្ភពីអនាគត់របស់នាងខ្ញុំណាស់"។* អ្នកស្រី បួរ ខាំតង, តំណាងសហគមន៍មកពីខេត្តស្ទឹងត្រែង

*"ប្រសិនបើទំនប់ដនសាហុងត្រូវបានសាងសង់ពិតមែន ប្រទេសឡាវនឹងបាត់បង់សត្វផ្សោតជារៀងរហូត ហើយសត្វផ្សោតដែលនៅសល់នៅប្រទេសកម្ពុជា នឹងបន្តបាត់បង់ផងដែរ!"* លោក ជេរី វ៉ាយអេន, ទីប្រឹក្សាបច្ចេកទេសរបស់ WWF កម្ពុជា

*"គ្មានផ្សោត គឺគ្មានទេសចរណ៍ ហើយក៏មិនមានចំណូលដែរ"* លោក ផ្លយ វណ្ណា តំណាងសហគមន៍ខេត្តក្រចេះ

*" យើងមិនអាចរស់នៅបានដោយគ្មានត្រីបានទេ ប៉ុន្តែ យើងអាចរស់នៅបាន ដោយគ្មានអគ្គិសនី"* លោក ឡុង សូចែត តំណាងបណ្តាញប្រជានេសាទ បឹងទន្លេសាប

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា រាល់បញ្ហា និងក្តីបារម្ភ ក៏ដូចជាសំណូមពរ ដែលបានលើកឡើងខាងលើនេះ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសវៀតណាម និងប្រទេសថៃ នឹងទទួលយកទៅពិចារណានៅក្នុងកិច្ចប្រជុំលើកទីពីរនូវកិច្ចប្រជុំកំពូលរបស់គណៈកម្មាធិការទន្លេមេគង្គ នៅប្រទេសវៀតណាម នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤ខាងមុខនេះ។

**ព័ត៌មានបន្ថែមសូមទំនាក់ទំនងមក៖**

១. អ្នកស្រី បួរ ខាំតង តំណាងសហគមន៍ទន្លេមេគង្គ, ទូរស័ព្ទ៖០៩៧ ៩៨១៣១៥៤
២.លោក តឹក វណ្ណារ៉ា តំណាងអង្គការសង្គមស៊ីវិល, ទូរស័ព្ទ៖ ០១២ ៧៩៣ ៤៨៩
៣.លោក ឡុង សូចែត តំណាងបណ្តាញប្រជានេសាទ បឹងទន្លេសាប, ទូរស័ព្ទ៖ ០១២ ៩៨៩ ៣១៨